រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

009KH01A-01

ព្រឹត្តិការណ៍សំខាន់ៗ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយអ្នកអោយអាចចាំពីព្រឹត្តិការណ៍សំខាន់ៗ នៅក្នុងប្រវត្តិសាស្ត្ររបស់ប្រជារាស្ត្រព្រះអង្គ តាមលំដាប់លំដោយ ។

ព្រះជាម្ចាស់បានប្រើព្រឹត្តការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ក្នុងរយៈពេលច្រើនសតវត្ស ដើម្បីរៀបចំបង្កើតប្រជារាស្ត្រមួយ ដែលស្ម័គ្រចិត្តថ្វាយបង្គំ និងបំរើព្រះអង្គអស់ពីចិត្ត ។

ព្រឹត្តិការណ៍ទី១មានចែងនៅក្នុងបទគម្ពីរកំណើតពិភពលោកជំពូក ទី ១ ។

ការបង្កើតរបស់ព្រះជាម្ចាស់

(កំណើតពិភពលោក ១-២)



កាលពីដើមដំបូងបង្អស់ព្រះជាម្ចាស់បង្កើតផ្ទៃមេឃ និងផែនដី ។..... ព្រះអង្គក៏បង្កើតរុក្ខជាតិគ្រប់យ៉ាង បក្សាបក្សី សត្វគ្រប់ប្រភេទ និងមនុស្សផងដែរ ។















២៤ _____

២៥ _____

២៦ _____

២៧ _____

២៨ _____

២៩ _____

៣០ _____

កិច្ចការដែលត្រូវអនុវត្ត

- ទន្ទេញព្រឹត្តិការណ៍តាមលំដាប់លំដោយអោយចាំ ហើយពន្យល់អត្ថន័យរបស់រឿងទាំងនោះដល់ មនុស្សដែលអ្នកបង្រៀន ។















๑๑ _____

๑๒ _____

๑๓ _____

๑๔ _____

๑๕ _____

๑๖ _____

๑๗ _____

๑๘ _____

๑๙ _____

๒๐ _____

๒๑ _____

๒๒ _____

๒๓ _____

អ្វីៗសព្វសារពើសុទ្ធតែត្រូវបង្កើតឡើងក្នុងសភាពល្អណាស់ ។ ប៉ុន្តែ មនុស្សបានប្រព្រឹត្តអំពើបាប ទើបអ្វីៗគ្រប់យ៉ាងក្លាយជាសៅហ្មង ដោយសារមនុស្សបានធ្លាក់ចុះក្នុងអំពើបាប ។

ការធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្ស

(កំណើតពិភពលោក ៣)



មារសាតាំងយករូបអង្គជាសត្វពស់
ដើម្បីបញ្ឆោត និងល្បួងមនុស្ស ។
អាដាម និងនាងអេវ៉ាបរិភោគផ្លែ
ឈើ ដែលព្រះជាម្ចាស់បានហាម
មិនអោយបរិភោគ ។ អ្នកទាំងពីរ
លែងស្តាប់បង្គាប់ព្រះជាម្ចាស់ ។
នេះជាអំពើបាបដំបូងបង្អស់របស់
មនុស្ស (អំពើបាបដើម) ។

កូនចៅរបស់អាដាមមានចិត្តកាន់តែអាក្រក់ទៅៗ ហើយធ្វើអោយពិភពលោកទាំងមូលក្លាយជាសៅហ្មង ។ ព្រះជាម្ចាស់ក៏សំរេចព្រះទ័យបំផ្លាញមនុស្សមានបាបទាំងអស់ ដោយធ្វើអោយមានទឹកជំនន់ ។

© Project WorldReach © SEAN

តើនរណាធ្វើអោយអំពើបាបចូលមកក្នុងពិភពលោក ហើយធ្វើអោយពិភពលោកទាំងមូលក្លាយជាសៅហ្មង ក្រៅពីអាដាម និងនាងអេវ៉ា ? ស_____។

ទឹកជំនន់

(កំណើតពិភពលោក ៧)



ព្រះជាម្ចាស់បំផ្លាញអ្វីៗគ្រប់យ៉ាងនៅលើផែនដី ដោយសារទឹកជំនន់ ។ ប៉ុន្តែ ព្រះអង្គសង្គ្រោះលោកណូអេ និងគ្រួសារគាត់ ។

នេះជាឱកាសថ្មីសំរាប់មនុស្សជាតិ ។ ប៉ុន្តែ កូនចៅរបស់លោកណូអេក្លាយជាពុករលួយដូចមនុស្សពីមុន ហើយពួកគេនាំគ្នាភ្លេចព្រះជាម្ចាស់ ។ នេះជាមូលហេតុ ដែលធ្វើឱ្យព្រះជាម្ចាស់ជ្រើសរើសមនុស្សម្នាក់ ដែលនឹងស្តាប់បង្គាប់ព្រះអង្គ ពីក្នុងចំណោមមនុស្សទាំងអស់ក្នុងពិភពលោក ។ មនុស្សនោះ ឈ្មោះលោកអាប្រាហាំ ។ ព្រះជាម្ចាស់សន្យាថានឹងបង្កើតប្រជាជាតិដ៏វិសុទ្ធ គឺថាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ពីពូជពង្សរបស់លោកអាប្រាហាំ។

ការប្រឡង (សំនួរសង្ខេបមេរៀន)

សូមសរសេរសេចក្តីដែលតំណាងរូបនិមួយៗ នៅទំព័របន្ទាប់ ។ បើសិនជាអ្នកមិនចាំ សូមមើលទំព័រមុនៗ ។







ការរីកសាយក្រុមជំនុំ



សព្វថ្ងៃនេះ យើងកំពុងស្ថិតនៅក្នុងរយៈពេល ដែលក្រុមជំនុំកំពុងរីកសាយ ។ ក្រុមជំនុំកំពុងរីកសាយទៅដល់ជាតិសាសន៍ទាំងអស់នៃពិភពលោកទាំងមូល ។

ព្រះយេស៊ូសន្យាថា នៅពេលដែលមនុស្សគ្រប់ជាតិសាសន៍បានឮដំណឹងល្អទាំងអស់គ្នាហើយ នោះអវសានកាលនៃពិភពលោកនឹងមកដល់ (ម៉ាថាយ ២៤: ១៤) ។

ព្រះជាម្ចាស់កំពុងរៀបចំប្រជារាស្ត្រមួយ ដែលថ្វាយបង្គំ និងបំរើព្រះអង្គអស់ពីចិត្ត និងដោយស្មគ្រៃចិត្ត ។ ប្រជារាស្ត្រនោះ គឺក្រុមជំនុំដែលព្រះយេស៊ូគ្រីស្តបានសង្គ្រោះ នឹងចូលមកក្នុងផែនដីថ្មីដែលព្រះជាម្ចាស់នឹងបង្កើត (២ ពេត្រុស ៣:១៣) ។

ព្រះជាម្ចាស់ចងសម្ពន្ធមេត្រីនេះជាមួយលោកអាប្រាហាំ ដែលជាជនជាតិហេប្រឺ (កូនចៅរបស់លោកហេប៊ែរ) ។

សម្ពន្ធមេត្រីជាមួយលោកអាប្រាហាំ

(កំណើតពិភពលោក ១២, ១៥)

ព្រះជាម្ចាស់សន្យាថា លោកអាប្រាហាំនឹងមានកូនចៅជាច្រើនដូចផ្កាយលើមេឃ ។ ពួកកូនចៅទាំងនោះ នឹងក្លាយជាប្រជាជាតិធំមួយ ។



ព្រះអង្គបានសន្យានឹងលោកអាប្រាហាំទៀតថា នឹងប្រទានទឹកដីមួយអោយប្រជាជាតិនោះ ។ ពួកយូដាសុទ្ធតែជាកូនចៅរបស់លោកអាប្រាហាំ ។ ហេតុនេះហើយបានជាពួកយូដាហៅលោកអាប្រាហាំថាជា «ឪពុក» ។ ពួកអ្នកជឿទាំងអស់សុទ្ធតែបានទទួលព្រះពរខាងព្រលឹងវិញ្ញាណ ដោយសារព្រះបន្ទូលសន្យា ដែលព្រះអង្គប្រទានអោយលោកអាប្រាហាំ ។ យើងរាល់គ្នាក៏ជាកូនរបស់លោកអាប្រាហាំដែរ ពីព្រោះយើងសុទ្ធតែមានជំនឿ ដូចលោកអាប្រាហាំ (រ៉ូម ៤:១៦-១៨) ។

លោកអាប្រាហាំជឿលើព្រះជាម្ចាស់ ។ ព្រះជាម្ចាស់ក៏ប្រទានពរ
អោយគាត់មានកូនប្រុសម្នាក់ឈ្មោះអ៊ីសាក់ ហើយកូនរបស់អ៊ីសាក់
គឺយ៉ាកុប ។

ព្រះជាម្ចាស់ក៏សន្យាថា នឹងប្រទានពរដល់ជាតិសាសន៍ទាំងអស់
ក្នុងពិភពលោក តាមរយៈពូជពង្សរបស់លោកអាប្រាហាំដែរ ។
សេចក្តីនេះបានសំរេចជារួបរាង ដោយសារការយាងមកបស់ព្រះ
គ្រីស្ត ដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាពូជពង្សរបស់
លោកអាប្រាហាំ ។

តើព្រះជាម្ចាស់បានជ្រើសរើសនរណា អោយធ្វើជាឪពុករបស់
ប្រជាជាតិថ្មី ដែលជាប្រជាជាតិអ៊ីស្រាអែល ? _____

តើព្រះជាម្ចាស់បានធ្វើឱ្យព្រះបន្ទូលសន្យារបស់ព្រះអង្គ ដែលថា
នឹងប្រទានពរដល់ប្រជាជាតិទាំងអស់ នៅក្នុងពិភពលោក បាន
សំរេច តាមរយៈពូជពង្សណាមួយរបស់លោកអប្រាហាំ ?_____

ព្រះជាម្ចាស់ប្រទានអោយលោកយ៉ាកុប (ចៅរបស់លោកអាប្រា-
ហាំ) មានឈ្មោះថា «អ៊ីស្រាអែល » ។ ហេតុនេះហើយបានជា
គេហៅកូនចៅរបស់គាត់ថា «កូនចៅអ៊ីស្រាអែល » ឬ «ពួក
អ៊ីស្រាអែល» ។

ការកែប្រែ



លោកម៉ាតាំងលូទែ (Martin Luther) បានចាប់ផ្តើមកែប្រែក្រុមជំនុំនៅប្រទេសអាល្លឺម៉ង់នៅដើមឆ្នាំ ១៥១៧ ។
ពួកប្រូតេស្តង់(Protestants)ទទួលស្គាល់ថា ព្រះគម្ពីរដ៏វិសុទ្ធដែលជាព្រះបន្ទូលព្រះជាម្ចាស់ ជារដ្ឋអំណាចធំបំផុតរបស់ពួកគ្រីស្តជន មិនមែនសម្តេច «ប៉ាប »ទេ ។ ពួកប្រូតេស្តង់បញ្ជាក់ថាយើងបានសង្គ្រោះ ដោយសារជំនឿ មិនមែនដោយសាការប្រព្រឹត្តល្អទេ ។

ការភ្ញាក់រលឹកផ្សព្វផ្សាយដំណឹងល្អ



កាលពីពីររយឆ្នាំមុន «ពួកគ្រីស្តជនដំណឹងល្អ»(Evangelicals)បញ្ជាក់ថាការដែលគ្រាន់តែស្គាល់គោលលទ្ធិរបស់ព្រះគម្ពីរ មិនទាន់គ្រប់គ្រាន់ទេ ។ មនុស្សត្រូវការស្គាល់ព្រះ-យេស៊ូគ្រីស្តដោយផ្ទាល់ និងកើតជាថ្មីដោយសារព្រះវិញ្ញាណដ៏វិសុទ្ធទៀត ។

សម័យកាលឆ្ងាងពន្លឺ



នៅក្នុងរយៈពេលចន្លោះពីគ. ស. ៥០០ទៅដល់គ. ស. ១000 រដ្ឋ-អំណាចដែលគ្រប់គ្រងជាតិសាសន៍នានាត្រូវចុះទន់ខ្សោយ ។ នៅពេលនោះ ការរៀនសូត្រ ឬ សិល្បៈមានតិចតួចណាស់ ។ ក្រុមជំនុំចុះខ្សោយ ដោយសារភាពល្ងង់ខ្លៅ ។

សង្គ្រាមសាសនា



សង្គ្រាមសាសនា ជាការដែលពួកទាហានប្រទេសអឺរ៉ុបខាងលិចចេញទៅវាយប្រឆាំងនឹងពួកជនជាតិទួរគីដែលកាន់កាប់ទឹកដីអ៊ីស្រាអែល ។ សង្គ្រាមសាសនានោះ ជាអំពើខុសឆ្គង ព្រោះពួកទាហានទាំងនោះខិតខំវាយរំដោះទឹកដីដ៏វិសុទ្ធរបស់ពួកអ៊ីស្រាអែល (ប្រទេសប៉ាឡេស្ទីន)មកវិញ ដោយសារមានចិត្តលោភលន់ ។ ពួកគេថែមទាំងវាយប្រហារ និងលួចប្លន់ទីក្រុងជាច្រើនរបស់គ្រីស្តជន ដែលស្ថិតនៅតាមផ្លូវ ដែលគេធ្វើដំណើរទៅទៀតផង ។

ព្រះជាម្ចាស់មានព្រះបន្ទូលប្រាប់លោកអាប្រាហាំថា ពួកកូនចៅរបស់គាត់នឹងក្លាយជាទាសករ នៅក្នុងប្រទេសអេស៊ីបអស់រយៈពេល៤00ឆ្នាំ ។ សេចក្តីនេះបានសំរេចជារូបរាង នៅពេលដែលលោកយ៉ាកុប (គឺកូនប្រុសរបស់អ៊ីសាក់ និងចៅរបស់លោកអាប្រាហាំ) ទៅនៅប្រទេសអេស៊ីប ដោយសារមានទុរ្ភិក្សកើតឡើង ។ យើងអាចឃើញរឿងរ៉ាវរបស់លោកអាប្រាហាំ និងគ្រួសាររបស់លោកនៅក្នុងសៀវភៅកំណើតពិភពលោក ។

ទាសភាពនៅក្នុងប្រទេសអេស៊ីប

(កំណើតពិភពលោក ៤៦, សេរីភាព ១)



លោកយ៉ាកុបមានកូនប្រុសដប់ពីរនាក់ ។ ពួកគេនាំគ្នាទៅនៅប្រទេសអេស៊ីប ដើម្បីរត់គេចពីទុរ្ភិក្ស ។ ពួកគេបង្កើតកូនចៅជាច្រើននៅទីនោះ គឺបង្កើតបានជាកុលសម្ពន្ធដប់ពីរ ។ ក្រោយមក ពួកអេស៊ីបធ្វើអោយពួកគេក្លាយជាទាសករ ។ ពួកគេរស់នៅយ៉ាងលំបាកបំផុត ហើយពួកគេស្រែកអំពាវអោយព្រះជាម្ចាស់ជួយ ។

ការរំដោះដោយការអស្ចារ្យ

(សេរីភាព ១២)



បន្ទាប់មក ព្រះជាម្ចាស់ចាត់តាំងលោកម៉ូសេឱ្យទៅរំដោះពួកគេ ។ ព្រះជាម្ចាស់ដាក់ទោសពួកអេស៊ីបដោយធ្វើអោយកើតមានគ្រោះកាចដប់យ៉ាង ។ បន្ទាប់មក ព្រះអង្គឆ្លងកាត់ប្រទេសអេស៊ីបទាំងមូលនៅពេលពាក់កណ្តាលអាធ្រាត្រ ហើយសម្លាប់កូនច្បងរបស់ពួកអេស៊ីបទាំងអស់ ។

ប៉ុន្តែ ពេលនោះ ព្រះអង្គមិនបានប៉ះពាល់ដល់កូនច្បងរបស់ពួកអ៊ីស្រាអែល ដែលបានយកឈាមមកលាបលើក្របទ្វារផ្ទះរបស់ពួកគេទេ ។

តើព្រះជាម្ចាស់ប្រើនរណា ដើម្បីរំដោះពួកអ៊ីស្រាអែលចេញពីប្រទេសអេស៊ីប ?

ការធ្លាក់ចុះរបស់ចក្រភពរ៉ូម



ចក្រភពរ៉ូម៉ាំងចុះអន់ខ្សោយក្នុងរយៈពេលច្រើនឆ្នាំ ។ នៅឆ្នាំ ៤៧៦ គ.ស. ចក្រភពរ៉ូម៉ាំងក៏រលត់រលាយទៅ នាំអោយអឺរ៉ុបខាងលិចមានការច្របូកច្របល់គ្មានច្បាប់មួយរយៈ ។

ការតែងតាំងសម្តេចសង្ឃនៅទីក្រុងរ៉ូម



សម្តេចសង្ឃនៅទីក្រុងរ៉ូម ត្រូវបានព្រះចៅអធិរាជរ៉ូម៉ាំងគាំទ្រ ។ សម្តេចសង្ឃនេះ ក៏មានអំណាចកាន់តែខ្លាំងឡើងៗលើគ្រូគង្វាលនិងសង្ឃឯទៀត ។ សម្តេចសង្ឃនេះទទួលឈ្មោះថា «សម្តេចប៉ាប» (Pope) ។ ក្រុមជំនុំមិនស្ងួរស្តាប់បង្គាប់ព្រះគ្រីស្តជាព្រះសិរសា ដូចពីមុនទៀតទេ គឺក្រុមជំនុំច្រើនតែធ្វើតាមរបៀបគ្រប់គ្រងរបស់ពួករ៉ូម៉ាំងទៅវិញ ។

ព្រះចៅអធិរាជកុងស្តង់ទីន (Constantine) ជាព្រះចៅអធិរាជរ៉ូម៉ាំង
ទីមួយ ដែលបានក្លាយជាគ្រីស្តជន ។ នៅឆ្នាំ ៣១៣ គ.ស.
(ក្រោយព្រះគ្រីស្តសុគត) ព្រះចៅអធិរាជនេះបានបង្កើត «បទ
បញ្ជត្តិនៅមីឡង់»ដែលការពារក្រុមជំនុំ ។ ក្រុមជំនុំដែលជាក្រុម
ជ័រិសុទ្ធនៃអ្នករួមជំនឿលើព្រះគ្រីស្ត បានក្លាយទៅជាស្ថាប័នមួយ
ដែលគាំទ្រ ដោយរដ្ឋាភិបាលរ៉ូម៉ាំង ហេតុនេះហើយបានជាក្រុម-
ជំនុំបាត់បង់ភាពស្អាតស្អំរបស់ខ្លួន ។

តើព្រះចៅអធិរាជទីមួយ ដែលក្លាយជាគ្រីស្តជន យ៉ាងគិចក៏មាន
ឈ្មោះជាគ្រីស្តជនដែរនោះ មាននាមដូចម្តេច ?

ការបង្កើតគោលជំនឿផ្សេងៗ



ដោយសារតែពួកគ្រីស្តជនជួបនឹង
គោលលទ្ធិក្លែងក្លាយ ទើបពួកគេ
បង្កើតគោលជំនឿ/Creed បន្តិច
ម្តងៗ ដែលជាសេចក្តីសង្ខេបអំពី
ជំនឿលើព្រះគ្រីស្ត ។
(គោលជំនឿនេះ តាមភាសាឡាតាំងគេហៅថា «គ្រីដដូ /Credo»
ដែលមានន័យថា «ខ្ញុំជឿ») ។

អ្នកដឹកនាំពួកអេស៊ីបអនុញ្ញាតិអោយពួកអ៊ីស្រាអែលចាកចេញពី
ប្រទេសអេស៊ីប ដោយសារព្រះជាម្ចាស់បានដាក់ទោសពួកអេស៊ីប
ដោយធ្វើអោយកើតមានគ្រោះកាច និងឱ្យកូនច្បងពួកគេស្លាប់ ។
ប៉ុន្តែ មិនយូរប៉ុន្មាន អ្នកដឹកនាំនោះប្តូរចិត្តទៀត ហើយអោយពួក
ទាហានអេស៊ីបចេញទៅដេញតាមពួកអ៊ីស្រាអែល ។

ព្រះជាម្ចាស់ញែកទឹកសមុទ្រក្រហម ដើម្បីអោយពួកអ៊ីស្រាអែល
ដើរលើដីស្ងួតឆ្លងកាត់សមុទ្រ ។ ប៉ុន្តែ នៅពេលដែលពួកទាហាន
អេស៊ីបចង់ឆ្លងតាមដែរ ព្រះជាម្ចាស់ក៏ពន្លិចពួកគេទៅក្នុងទឹក
សមុទ្រ ។

បន្ទាប់មក ប្រជារាស្ត្រព្រះជាម្ចាស់ធ្វើដំណើរក្នុងវាលរហោស្ថាន។
ព្រះជាម្ចាស់បានប្រទានក្រិត្យវិន័យរបស់ព្រះអង្គដល់ប្រជារាស្ត្រ
ព្រះអង្គ តាមរយៈលោកម៉ូសេដែលជាអ្នកសម្រុះសម្រួល ។

ក្រិត្យវិន័យ

(សេរីភាព ២០)



ពួកអ៊ីស្រាអែលបានទទួល
ក្រិត្យវិន័យនៅលើភ្នំស៊ីណាយ ។

ព្រះជាម្ចាស់ចង់នាំពួកគេទៅទឹកដី ដែលព្រះអង្គបានសន្យាជាមួយលោកអាប្រាហាំ ។ ប៉ុន្តែបណ្តាជនមិនស្តាប់បង្គាប់ព្រះជាម្ចាស់ទេ ទើបពួកគេនៅវិលវល់ក្នុងទីរហោស្ថានសែសិបឆ្នាំ ។

នៅពេលដែលពួកអ្នកមិនស្តាប់បង្គាប់ស្លាប់អស់ទៅ ទើបព្រះ-ជាម្ចាស់ដឹកនាំប្រជារាស្ត្រព្រះអង្គទៅទឹកដីសន្យា ។ តែនៅក្នុងទឹកដីនោះ មានជាតិសាសន៍ដែលមិនស្គាល់ព្រះជាម្ចាស់រស់នៅ ។ ពួកអ៊ីស្រាអែលត្រូវវាយយកឈ្នះលើពួកជាតិសាសន៍ទាំងនោះ ។

ការចាកចេញពីប្រទេសអេស៊ីប ការឆ្លងកាត់វាលរហោស្ថាន និង ក្រិត្យវិន័យរបស់លោកម៉ូសេ មានសរសេរទុកនៅក្នុងសៀវភៅ-សេរីភាព លេវីវិន័យ ជំរឿនប្រជាជន និង ទុតិយកថា ។

ក្រុមជំនុំដំបូងបង្អស់ផ្សាយដំណឹងល្អ ធ្វើអោយក្រុមជំនុំរីកចំរើនយ៉ាងឆាប់រហ័ស ។ ពួកគេធ្វើតាមគំរូរបស់ពួកសាវ័ក ។ ព្រះ-គ្រីស្តបញ្ជូនព្រះវិញ្ញាណដ៏វិសុទ្ធអោយយាងមក ដើម្បីអោយសាវ័កទាំងអស់ទទួលបុទ្ធានុភាព សំរាប់ផ្សព្វផ្សាយដំណឹងល្អថ្វាយព្រះ-អង្គ ។

តើអ្នកណាប្រទានកំឡាំង និងអំណាចអោយយើង សំរាប់ផ្សាយដំណឹងល្អ ?_____

ចាប់ពីត្រឹមនេះទៅ ប្រវត្តិសាស្ត្រក្រុមជំនុំ គ្មាននៅក្នុងព្រះគម្ពីរទេ តែមាននៅក្នុងឯកសារប្រវត្តិសាស្ត្របុរាណវិញ ។

ការថ្វាយខ្លួនរបស់ព្រះចៅអធិរាជកុងស្តង់ទីន



ពួកព្រះចៅអធិរាជរ៉ូម៉ាំងបានបៀត
បៀនពួកគ្រីស្តជន ធ្វើឱ្យគ្រីស្តជន
ជាច្រើនស្លាប់ ។ តែទោះជាយ៉ាង
នេះក៏ដោយ ក៏ក្រុមជំនុំរីកចំរើន
យ៉ាងឆាប់រហ័ស នៅក្នុងចក្រភពទាំងមូល និងនៅខាងក្រៅ ចក្រភពដែរ (គឺនៅក្នុងផ្នែកអាស៊ី អឺរ៉ុប និងអាហ្វ្រិកខាងជើង)។

កំណើតក្រុមគ្រីស្តបរិស័ទ ដែលហៅថាក្រុមជំនុំ (ក្រុមជំនុំរបស់ពួកសាវ័កដំបូង)

(កិច្ចការ និង សំបុត្ររបស់ពួកសាវ័ក)



ព្រះយេស៊ូបញ្ជូនពួកសាវ័ករបស់ព្រះអង្គអោយទៅផ្សព្វផ្សាយដំណឹងល្អដល់គ្រប់ជាតិសាសន៍ ។ ព្រះ-អង្គបង្គាប់អោយពួកគេនិយាយអំពីការកែប្រែចិត្ត និងការដែលព្រះជាម្ចាស់លើកលែងទោសអំពើបាប ដោយសារព្រះនាមព្រះយេស៊ូ តាមរយៈទ្វានុភាពរបស់ព្រះ-វិញ្ញាណដ៏វិសុទ្ធ (លូកា ២៤:៤៦-៤៩, កិច្ចការ ១:៨) ។

ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកជាលើកដំបូង មកសណ្ឋិតលើពួកអ្នកជឿយូដា នៅថៃទីហាសិប ។ បន្ទាប់មក ព្រះអង្គយាងមកសណ្ឋិតលើពួកសាសន៍ដទៃ នៅពេលដែលលោកពេត្រុសបានផ្សព្វផ្សាយដំណឹងល្អនៅផ្ទះរបស់លោកគ័រនេលាូស ។

ការវាយដណ្តើមយកទឹកដី

(យ៉ូស៊ូអា)



លោកយ៉ូស៊ូអាធ្វើជាអ្នកដឹកនាំទ័ពរបស់ព្រះជាម្ចាស់ ។ ពួកគេវាយលុកចូលទឹកដីសន្យា ហើយយកជ័យជំនះលើពួកអ្នកគោរពព្រះ-ក្លែងក្លាយ ដែលរស់នៅទីនោះ ។ តែនៅពេលដែលពួកអ៊ីស្រាអែលបានសុខហើយ ពួកគេក៏ភ្លេចព្រះជាម្ចាស់ ។ ព្រះជាម្ចាស់ក៏នាំអោយជាតិសាសន៍ដទៃទាស់នឹងពួកគេ ដើម្បីដាក់ទោសពួកគេ ។ នៅពេលដែលពួកគេកែប្រែចិត្តគំនិត ព្រះអង្គក៏បញ្ជូនពួកវីរៈបុរសអោយមករៀបចំសណ្តាប់ធ្នាប់ឡើងវិញ ។

ការគ្រប់គ្រងរបស់ពួកវីរៈបុរស

(វីរៈបុរស)



នៅពេលដែលពួកអ៊ីស្រាអែល....
ចាប់ផ្តើមថ្វាយបង្គំព្រះផ្សេងៗទៀត
ព្រះជាម្ចាស់ក៏ដាក់ទោសពួកគេ
ដោយអោយជាតិសាសន៍ដទៃមក
ឈ្លានពានពួកគេ ។

នៅពេលដែលពួកអ៊ីស្រាអែលកែប្រែចិត្តគំនិត ព្រះជាម្ចាស់រំដោះពួកគេពីសត្រូវ ដោយសារវីរៈបុរសម្នាក់ ហើយពួកគេក៏បានសុខរហូតដល់ពេលដែលពួកគេធ្វើអំពើបាបទៀត ។ ហេតុការណ៍ដូចនេះកើតមានជាច្រើនដង ។

ការគ្រប់គ្រងរបស់ពួកវីរៈបុរស មានសរសេរទុកនៅក្នុងសៀវភៅវិរបុរស នាង៉ូថ និង ១ សាំមូអែល ។ ក្រោយមក ពួកអ៊ីស្រាអែលលែងចង់ទទួលពួកវីរៈបុរសជាអ្នកគ្រប់គ្រងទៀត ក៏ទូលសូមអោយមានស្តេចគ្រប់គ្រងវិញ ។ ព្រះជាម្ចាស់ក៏ប្រទានសាអ៊ូលអោយមកធ្វើជាស្តេចគ្រប់គ្រងលើពួកគេ ។

ព្រះយេស៊ូគ្រីស្តធ្វើកិច្ចការបំរើមហាជនតែបីឆ្នាំទេ ។ ព្រះអង្គផ្សព្វផ្សាយដំណឹងល្អ បង្រៀន និងបង្ហាត់ពួកសិស្សរបស់ទ្រង់ ។ យើងឃើញសេចក្តីរៀបរាប់អំពីដំណើរជីវិត និងសេចក្តីបង្រៀនរបស់ព្រះអម្ចាស់យេស៊ូ នៅក្នុងសៀវភៅដំណឹងល្អ ។

ការសុគត និង ការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូគ្រីស្ត



ព្រះយេស៊ូគ្រីស្ត ដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ ជាកូនចៀម
ដែលសុគតដើម្បីយើង ។ ព្រះ-
ជាម្ចាស់ នឹងលើកលែងទោសអំពើ
បាបរបស់យើង បើសិនជាយើងជឿ
លើព្រះយេស៊ូគ្រីស្ត ។

ក្រោយដែលព្រះយេស៊ូគ្រីស្តមានព្រះជន្មរស់ឡើងវិញហើយ ព្រះអង្គបង្គាប់សាវ័ករបស់ព្រះអង្គអោយចេញទៅផ្សព្វផ្សាយដំណឹងល្អពាសពេញពិភពលោក ។ បន្ទាប់មក ព្រះអង្គក៏យាងឡើងទៅស្ថានបរមសុខ ។ ពេលឥឡូវនេះ មនុស្សគ្រប់រូប ទាំងយូដា ទាំងជាតិសាសន៍ឯទៀតអាចក្លាយជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដោយជឿលើព្រះយេស៊ូគ្រីស្ត ។

© Project WorldReach © SEAN

សម្ពន្ធមេត្រីថ្មីចាប់ផ្តើម :

កំណើតរបស់ព្រះយេស៊ូគ្រីស្ត



(ម៉ាថាយ ម៉ាកុស លូកា និង យ៉ូហាន) ។

នៅពេលដែលព្រះយេស៊ូគ្រីស្ត
ប្រសូត ចក្រភព្រ៉ូមគ្រប់គ្រងលើ
បណ្តាប្រទេសនៅជុំវិញសមុទ្រ
មេឌីទែរ៉ាណេ ។ ព្រះអម្ចាស់របស់យើងចាប់ផ្តើមធ្វើកិច្ចការបំរើ
មហាជន នៅពេលដែលព្រះអង្គមានវ័យ៣០ឆ្នាំ ។

កិច្ចការបំរើរបស់ព្រះយេស៊ូគ្រីស្ត



(រូបត្រីបានក្លាយជានិមិត្តសញ្ញា
របស់ពួកគ្រីស្តជន ច្រើនសតវត្ស
ពីព្រោះក្នុងភាសាក្រិក តួអក្សរ
ដែលនៅក្នុងពាក្យ «ត្រី» បង្កើត
ជាពាក្យ «ព្រះយេស៊ូ ព្រះគ្រីស្ត
ព្រះបុត្រាព្រះជាម្ចាស់ និង
ព្រះសង្គ្រោះ») ។

ការចាប់ផ្តើមរាជាណាចក្រ

(១ សាំមូអែល ៩)



ស្តេចដំបូងបីអង្គ គឺស្តេចសាអ៊ូល
ស្តេចដាវីឌ និងស្តេចសាឡូម៉ូន ។
ស្តេចដាវីឌវាយដណ្តើមបានទឹកដី
ជាច្រើន ហើយបានធ្វើអោយ
រាជាណាចក្រមានសណ្តាប់ធ្នាប់
និងបានចំរុងចំរើន ។

ព្រះជាម្ចាស់បានចងសម្ពន្ធមេត្រីជាមួយស្តេចដាវីឌ ។ ព្រះជាម្ចាស់
បានសន្យាថានឹងប្រទានព្រះមហាក្សត្រពិសេសមួយអង្គ ដែលជា
ពូជពង្សស្តេចដាវីឌ ដែលនឹងគ្រងរាជ្យជារៀងរហូត ។ នាងម៉ារី
ជាម្តាយរបស់ព្រះយេស៊ូ និងលោកយ៉ូសែប ជាឪពុកចិញ្ចឹមរបស់
ព្រះអង្គ សុទ្ធតែជាពូជពង្សស្តេចដាវីឌទាំងពីរនាក់ ។

ពាក្យទំនាយគ្រប់យ៉ាងអំពីពូជពង្សរបស់ស្តេចដាវីឌម្នាក់ ដែលនឹង
គ្រងរាជ្យជារៀងរហូត បានសំរេចជារូបរាង ដោយសារព្រះ-
អម្ចាស់យេស៊ូគ្រីស្ត ។

ព្រះជាម្ចាស់ចងសម្ពន្ធមេត្រីជាមួយស្តេចដាវីឌ អំពីការធ្វើអោយ មានពួជពង្សរបស់ស្តេចដាវីឌម្នាក់ ដែលនៅស្ថិតស្ថេរជាដរាបតទៅ ។ តើព្រះជាម្ចាស់ធ្វើអោយសេចក្តីសន្យានេះ បានសំរេចជារូបរាង ដោយសារនរណា ?_____

ស្តេចទីបីឈ្មោះសាឡូម៉ូន ដែលជាបុត្រដ៏ឈ្លាសវៃរបស់ស្តេចដាវីឌ បានកសាងព្រះវិហារដំបូង ។

ការកសាងព្រះវិហារ

(១ ពង្សាវតាក្សត្រ ៦)

ព្រះវិហារដែលស្តេចសាឡូម៉ូនបានកសាងស្អាត ហើយល្បីល្បាញពេញពិភពលោក ។ ព្រះវិហារនេះ តំណាងវត្តមានរបស់ព្រះជាម្ចាស់ក្នុងចំណោមប្រជារាស្ត្រព្រះអង្គ ។ ពួកអ៊ីស្រាអែលថ្វាយសត្វជាយញ្ញបូជានៅទីនោះ នេះជានិមិត្តរូបអំពីការសុគតរបស់ព្រះគ្រីស្ត ដើម្បីយើង ។



សេរីភាពបានដោយសារពួកម៉ាកាប៊ី



មនុស្សម្នាក់ឈ្មោះ «យូដាសម៉ាកាប៊ែរ» (ដែលគេហៅថា «ញញ្ជូរ ») បានធ្វើអោយ សេរីភាពមួយរយៈខ្លីនោះ ។ សៀវភៅទាំងឡាយនៅក្នុងសម្ពន្ធមេត្រីចាស់គ្មាននិយាយអំពីហេតុការណ៍នេះទេ ។ ពីព្រោះ ហេតុការណ៍នេះ កើតឡើងនៅក្នុងរយៈពេលចន្លោះសម្ពន្ធមេត្រីចាស់ និងសម្ពន្ធមេត្រីថ្មី មុនព្រះគ្រីស្តប្រសូត ។ នៅពេលនោះ ពួករ៉ូមុាំងចាប់ផ្តើមវាយយកពិភពលោកហើយ ។

ចក្រភពរ៉ូមុាំងចាប់ផ្តើមកកើត

ពួករ៉ូមុាំងគ្រប់គ្រងលើពិភពលោក ជាង៥០០ឆ្នាំ ។ ពួកគេគ្រប់គ្រងលើទឹកដីរបស់ពួកយូដា (នៅពេលនោះ ពួកគេហៅទឹកដីនោះថា «ប្រទេសប៉ាឡេស្ទីន») នៅសម័យកាល ដែលព្រះអម្ចាស់យេស៊ូប្រសូត ។



អ្នកដឹកនាំ ដែលបានកសាងទីក្រុងយេរូសាឡឹមឡើងវិញ ។ ប៉ុន្តែនៅពេលដែលពួកយូដាត្រឡប់មកនៅប្រទេសខ្លួនវិញ ពួកគេមិនមែនមានសេរីភាពពេញលេញទេ ។ ពួកគេត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់អំណាចបរទេសជាច្រើនទៀត ។

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេស



នៅពេលដែលរាជាណាចក្រយូដាបានកកើតឡើងវិញ ពួកអ៊ីស្រាអែលស្ថិតក្រោមការគ្រប់គ្រងរបស់ពួកពែរ្ស ពួកក្រិក និងពួកស៊ីរី ។ ពួកយូដាមិនព្រមស្ថិតនៅក្រោមការគ្រប់គ្រងរបស់បរទេសទេ ។ ហេតុដូចនេះ ទើបពួកគេព្យាយាមសាកល្បងបះបោរច្រើនដង ។ ពួកគេមានសេរីភាពមួយរយៈពេលខ្លី ដោយសារពួក «ម៉ាកាប៊ី» បានរំដោះពួកគេ ។

តែគួរអោយសោកស្តាយ ព្រោះនៅពេលដែលស្តេចសាឡូម៉ូនមានវ័យចាស់ទៅ ទ្រង់ងាកចេញពីព្រះជាម្ចាស់ទៅបំរើព្រះក្លែងក្លាយវិញ ។ ព្រះជាម្ចាស់ក៏ដាក់ទោសស្តេចសាឡូម៉ូន ដោយអោយកូនចៅស្តេចសាឡូម៉ូនគ្រប់គ្រងតែលើកុលសម្ព័ន្ធយូដាមួយប៉ុណ្ណោះ ។ កុលសម្ព័ន្ធឯទៀតបានរួមគ្នាបង្កើតរាជាណាចក្រមួយផ្សេងទៀត ។

រាជាណាចក្របែកចេញពីគ្នា

(១ ពង្សាវតាក្សត្រ ១២)



កុលសម្ព័ន្ធទាំងដប់ពីររបស់ពួកអ៊ីស្រាអែលបានបែកចេញពីគ្នា ។ កុលសម្ព័ន្ធដប់នៅភាគខាងជើងបង្កើតរាជាណាចក្រអ៊ីស្រាអែល ។ កុលសម្ព័ន្ធនៅភាគខាងត្បូងបង្កើតរាជាណាចក្រយូដា ។ (នេះជាប្រភពដើមនៃឈ្មោះ«យូដា» ។ សព្វថ្ងៃនេះ កូនចៅអ៊ីស្រាអែលទាំងអស់សុទ្ធតែមានឈ្មោះថាយូដា ទោះជាពួកគេមកពីកុលសម្ព័ន្ធផ្សេងៗក៏ដោយ) ។ក្រោយពេលដែលពួកអ៊ីស្រាអែលបែកបាក់គ្នាបង្កើតជារាជាណាចក្រពីរ គឺអ៊ីស្រាអែល និងយូដា ពួកគេក្លាយជាទន់ខ្សោយ ។ ពួកគេច្រើនតែមិនស្តាប់បង្គាប់

ព្រះជាម្ចាស់ ហើយបែរជាថ្វាយបង្គំព្រះក្លែងក្លាយវិញ ។ ពួកព្យាការីរបស់ព្រះជាម្ចាស់បានព្រមានពួកគេ តែពួកគេមិនយកចិត្តទុកដាក់ស្តាប់ទេ ។ ហេតុនេះ ទើបព្រះជាម្ចាស់ត្រូវដាក់ទោសពួកគេ ។

តើរាជាណាចក្ររបស់ស្តេចសាឡូម៉ូនត្រូវបានបែងចែកជារាជាណាចក្រអ្វីខ្លះ ?_____

សេចក្តីរៀបរាប់អំពីស្តេច និង រាជាណាចក្រទាំងពីរ មានកត់ត្រាទុកក្នុងសៀវភៅសាំមូអែលទី ១ និង ទី ២, ពង្សាវតាក្សត្រ ទី ១ និង ទី ២, របាក្សត្រ ទី ១ និង ទី ២ ។
ពាក្យព្រមានរបស់ពួកព្យាការីមាន កត់ត្រាទុកនៅក្នុងសៀវភៅ-អេសាយ យេរេមី និងសៀវភៅព្យាការីផ្សេងៗទៀត ។

ព្រះជាម្ចាស់អនុញ្ញាតិអោយស្តេចប្រទេសអាស្ស៊ីរីនិរទេសមនុស្សចេញពីក្នុងរាជាណាចក្រអ៊ីស្រាអែល ។ ជាងមួយរយឆ្នាំក្រោយមក ស្តេចប្រទេសបាប៊ីឡូនបានកំទេចទីក្រុងយេរូសាឡឹម ដែលជារាជធានីរាជាណាចក្រយូដា ហើយនាំប្រជាជាតិនេះជាឈ្លើយទៅនៅប្រទេសបាប៊ីឡូន ។

ការជាប់ជាឈ្លើយសឹកនៅប្រទេសបាប៊ីឡូន

(២ ពង្សាវតាក្សត្រ ២៥)



ពួកយូដាត្រូវនិរទេសទៅនៅប្រទេសបាប៊ីឡូន ។ នៅទីនោះ ពួកគេកែប្រែចិត្ត លែងថ្វាយបង្គំព្រះក្លែងក្លាយ ហើយពួកគេក៏បានស្តាប់បង្គាប់ព្រះជាម្ចាស់វិញ ។ ពួកគេនាំគ្នាអំពាវនាវរកព្រះជាម្ចាស់ជាថ្មីម្តងទៀត ដើម្បីទូលសុំអោយព្រះអង្គជួយរំដោះពួកគេ ។ ព្រះជាម្ចាស់ក៏អនុញ្ញាតិអោយពួកគេបានវិលមកស្រុកទេសវិញ ។

ការវិលត្រឡប់មកស្រុកទេស

(អែសរ៉ា ១)



ពួកពែរ្សបានមកឈ្លានពានចក្រភពបាប៊ីឡូន ។ ហើយពួកពែរ្សបានអនុញ្ញាតិអោយពួកយូដាវិលត្រលប់ទៅប្រទេសខ្លួនវិញ ។ លោកអែសរ៉ា និងលោកនេហេមីជាពួក